អង្គការមូលនិធិ ម៉េងលី ជេ. គួច
Mengly J. Quach Foundation
A Mengly J. Quach Education

របាយការណ៍

ប្រចាំឆ្នាំ

២០១៩

មាតិកា

កម្មវិធីអប់រំ (ទំព័រ ៤)

- គម្រោង កង់សម្រាប់ការអប់រំកុមារ
- គម្រោង សាងសង់សាលារដ្ឋ ម៉េងលី ជេ. គួច
- គម្រោង អាហារូបករណ៍ ម៉េងលី ជេ. គួច
- គម្រោង បណ្ណាល័យចល័ត ម៉េងលី ជេ. គួច
- គម្រោង គុណភាព ការបង្រៀន និងការសិក្សា
- គម្រោង សិក្ខាសាលាសប្បុរសធម៌ ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី

កម្មវិធី សុខភាព (ទំព័រ ១០)

- គម្រោង ឆ្លើយតបសង្គ្រោះបន្ទាន់ផ្នែកសុខភាព
- គម្រោង ធនាគារឈាម ម៉េងលី ជេ. គួច
- គម្រោង គ្លីនិកព្យាបាលចល័ត វេជ្ជបណ្ឌិត គួច
- គម្រោង សាងសង់ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល
- គម្រោង មណ្ឌលថែទាំចាស់ជរា ម៉េងលី ជេ. គួច

កម្មវិធី សេវាសហគមន៍(ទំព័រ ១៣)

- គម្រោង ឆ្លើយតបសង្គ្រោះបន្ទាន់
- គម្រោង ធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច
- គម្រោង សាងសង់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍
- គម្រោង អំណោយសប្បុរសធម៌
- គម្រោង គំនិតផ្តួចផ្តើមអាជីវកម្មវៃឆ្លាត

អក្សរកាត់

BoD	Board of Directors
CCC	Cooperation Committee for Cambodia
CICAH	Cambodian Institute of Child and Adolescent Health
CSR	Corporate Social Responsibility
ED	Executive Director
GGEAR	Geriatrics and Gerontology Education and Research
GIK	Gift In Kind
IB	Intercon Book Store
ITD	Information Technology Development
ITS	Inter-con Transportation Services
MJQE	Mengly J. Quach Education
MJQF	Mengly J. Quach Foundation
MJQTV	Mengly J. Quach Television
MoEF	Ministry of Economy and Finance
MoEYS	Ministry of Education Youth and Sport
MoI	Ministry of Interior
NGO	Non-Governmental Organization
PR	Purchase Order
ToR	Term of Reference
Q & Q	Quach and Quach

លិខិតពីអ្នកស្រី យូ ម៉ាលែន
ប្រធានគ្រប់គ្រងកម្មវិធីនៃអង្គការមូលនិធិ ម៉េងលី ជេ. គួច

ជម្រាបសួរលោក លោកស្រី និងអ្នកគាំទ្ររបស់យើងខ្ញុំទាំងអស់គ្នាជាគោរព និងរាប់អាន!

របាយការណ៍ប្រចាំឆ្នាំ២០១៩ ពីពណ៌នាពីសមិទ្ធផលយ៉ាងធំធេងរបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច ក្នុងការផ្តល់សេវាកម្ម និងអនុវត្តកម្មវិធីដើម្បីផ្តល់ផលប្រយោជន៍ដល់អ្នកទទួលផលនានា ដោយមានកិច្ចសហការជាមួយអង្គការដៃគូ អាជ្ញាធរមូលដ្ឋាន ម្ចាស់ជំនួយ និងអ្នកផ្គត់ផ្គង់សេវាកម្មនានាផងដែរ។ របាយការណ៍នេះបានដាក់បញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុសង្ខេបដែលត្រូវបានពិពណ៌នាអំពីការប្រើប្រាស់ធនធាននៅក្នុងឆ្នាំធ្វើរបាយការណ៍។

ក្នុងឆ្នាំ២០១៩ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានអនុវត្តកម្មវិធីចំនួន៣ ក្នុងចំណោមកម្មវិធីទាំង៤ ដោយក្នុងនោះមានគម្រោងដែលត្រូវបានអនុវត្តចំនួន១៥ក្នុងចំណោមគម្រោងទាំង២០។ កម្មវិធីដែលត្រូវបានអនុវត្តក្នុងឆ្នាំ ២០១៩នេះរួមមាន កម្មវិធី អប់រំ កម្មវិធី សុខភាព និងកម្មវិធីអភិវឌ្ឍសេវាសហគមន៍ ដើម្បីឆ្លើយតបតម្រូវការចាំបាច់នៅតាមសហគមន៍នានាក្នុងតំបន់ជនបទដាច់ស្រយាល និងតំបន់ជាយក្រុង។ ក្នុងឆ្នាំ២០១៩ ផងដែរ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងពេញលេញ ហើយបុគ្គលិកទាំងអស់ក្នុងស្ថាប័នត្រូវបានកំណត់តួនាទី និងបែងចែកការទទួលខុសត្រូវលើការងាររបស់ខ្លួន ហើយបុគ្គលិកម្នាក់ៗបានយល់ច្បាស់អំពីរំហូរការងារ និងគោលនយោបាយដែលស្ថាប័នមានផងដែរ ដែលក្នុងនោះក្រុមការងារបានសម្រេចសមិទ្ធិផលធំៗគួរឱ្យកត់សម្គាល់ ដូចខាងក្រោម៖

ក. ភាពជាដៃគូ និងការអនុវត្តពេញលេញជាអង្គការមិនមែនរដ្ឋាភិបាល៖

- ✓ អង្គការមូលនិធិ ម៉េងលី ជេ. គួច ត្រូវបានទទួលស្គាល់ជាសមាជិករបស់អង្គការគណៈកម្មការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩។ តំណាងរបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំក្រុមបណ្ដាញការងារ និងសិក្ខាសាលានានាដែលអង្គការ CCC បានរៀបចំឡើងជាមួយសមាជិកអង្គការដទៃទៀត។
- ✓ ការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច ត្រូវបានធ្វើឡើងដើម្បីឱ្យមានលក្ខណៈពេញលេញ និងសមស្របតាមច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានអនុម័តដោយរដ្ឋសភាកាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥។
- ✓ អង្គការមូលនិធិ ម៉េងលី ជេ. គួច កំពុងស្ថិតក្នុងដំណើរការរៀបចំអនុសារណៈយោគយល់ជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអនុវត្តកម្មវិធីអប់រំឱ្យបានទូលំទូលាយ។ រហូតដល់ពេលនេះ អង្គការមូលនិធិ ម៉េងលី ជេ. គួច ទទួលបានលិខិតគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង។

- ✓ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានជួបពិភាក្សាជាមួយក្រុមហ៊ុន GGEAR Group ដើម្បីបង្កើតកិច្ចសហការលើទំនួលខុសត្រូវការងារសង្គម និងការពិភាក្សារៀបចំគម្រោងបណ្ណាល័យចល័តប្រចាំឆ្នាំ២០២០។
- ✓ នីតិវិធីរំហូរការងារជាមួយផ្នែក/អង្គភាពនានាក្នុងក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ត្រូវបានបង្កើតឡើង និងត្រូវបានយកមកអនុវត្តយ៉ាងពេញលេញ។
- ✓ ព្រឹត្តិការណ៍សង្គម ឬសប្បុរសធម៌ដែលត្រូវបានរៀបចំឡើងដោយលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ត្រូវបានចូលរួលសម្របសម្រួលដោយក្រុមការងាររបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច។

ខ. តម្លាភាព និងគណនេយ្យភាព អង្គការៈ

- ✓ សវនកម្មផ្ទៃក្នុងត្រូវបានធ្វើឡើងកាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ ដោយទទួលបានលទ្ធផលល្អប្រសើរ គ្មានកំណត់ត្រាហានិភ័យគួរឱ្យកត់សម្គាល់។
- ✓ គោលនយោបាយចំនួន១០របស់អង្គការមូលនិធិ ម៉េងលី ជេ. គួច ត្រូវបានរៀបចំតាក់តែងឡើង ដើម្បីធ្វើការពង្រឹងការគ្រប់គ្រងផ្ទៃក្នុងរបស់អង្គការ។ ស្របពេលជាមួយគ្នា សកម្មភាពការងារសង្គម និងសប្បុរសធម៌ ត្រូវបានអនុវត្ត ដោយផ្អែកតាមគោលការណ៍ណែនាំ និងនីតិវិធីដែលបានចែងក្នុងគោលនយោបាយទាំងអស់ផងដែរ។

គ. ការរៀបចំឯកសារប្រវត្តិសាស្ត្រ

- ✓ ឯកសារប្រវត្តិសាស្ត្រចាប់ពីឆ្នាំ២០០៦ដល់ឆ្នាំ២០១៩ ត្រូវបានបញ្ចប់សព្វគ្រប់ ដោយឯកសារទាំងអស់ត្រូវបានបោះពុម្ពចេញ និងត្រូវបានដាក់ជូនទៅកាន់ការិយាល័យរបស់នាយកប្រតិបត្តិ។
- ✓ លិខិតថ្លែងអំណរគុណចំនួន២៥សន្លឹករបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច ត្រូវបានស្កេន និងបញ្ជូនច្បាប់ដើមជូនទៅការិយាល័យរបស់លោកនាយកប្រតិបត្តិ។
- ✓ កម្រងរូបថតសកម្មភាពរបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច ចាប់ពីឆ្នាំ២០០៦ដល់ឆ្នាំ២០១៩ ត្រូវបានត្រួតពិនិត្យ ជ្រើសរើសបានប្រមាណ៩០% ដោយរំពឹងថានឹងត្រូវបានបញ្ចប់រួចរាល់នៅចុងខែកុម្ភៈ ឆ្នាំ២០២០។

ឃ. ការផ្សព្វផ្សាយ និងការផ្សារភ្ជាប់ទំនាក់ទំនង

- ✓ គេហទំព័ររបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច ត្រូវបានបង្កើតឡើង និងត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ផ្អែកតាមព្រឹត្តិការណ៍ ឬសកម្មភាពរបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច។
- ✓ គណនីធនាគារនៅធនាគារ ABA ត្រូវបានស្នើសុំបង្កើតឡើង ដើម្បីបង្កភាពងាយស្រួលសម្រាប់សប្បុរសជនធ្វើការបរិច្ចាគថវិកាដើម្បីចូលរួមចំណែកការងារសង្គម និងសប្បុរសធម៌របស់អង្គការមូលនិធិ ម៉េងលី ជេ. គួច។

- ✓ កូនសៀវភៅព្រឹត្តិប័ត្រព័ត៌មានរបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច ត្រូវបានពង្រាង និងត្រូវបានរំពឹងថានឹងធ្វើរួចរាល់ ព្រមទាំងទម្លាក់ទៅឱ្យផ្នែកព័ត៌មានវិទ្យាដើម្បីតាក់តែងរូបរាងនៅអំឡុងខែមីនា ឆ្នាំ២០២០ ខណៈឯកសារដែលនៅសេសសល់ផ្សេងទៀតដូចជា ខិតបណ្ណផ្សព្វផ្សាយ បណ្ណព័ត៌មានអំពីទស្សនៈវិស័យ បេសកកម្ម និងគោលដៅ និងឯកសារផ្សេងទៀតនឹងត្រូវបានធ្វើរួចរាល់ក្នុងឆ្នាំ២០២០។

ង. និរន្តរភាពហិរញ្ញវត្ថុ

- ✓ ការបរិច្ចាគ របស់បុគ្គលិក និងលោកគ្រូ អ្នកគ្រូ ត្រូវបានធ្វើឡើងជាប្រចាំខែ ដើម្បីបង្កើនមូលនិធិក្នុងអង្គការសម្រាប់ធ្វើសកម្មភាពសង្គម និងសប្បុរសធម៌។
- ✓ ក្រៅពីការទទួលបានការបរិច្ចាគថវិកាប្រចាំខែ អង្គការមូលនិធិ ម៉េងលី ជេ. គួច តែងតែទទួលបានការបរិច្ចាគជាថវិកា និងសម្ភារនៅតាមប្រអប់សប្បុរសធម៌នានាដែលត្រូវបានដាក់តាមសាខាទាំងអស់នៃសាលារៀន អន្តរទ្វីប អាមេរិកាំង និងមជ្ឈមណ្ឌលភាសា អេ អាយ អាយ។

ទោះជាយ៉ាងណាក្តី យើងខ្ញុំទាំងអស់គ្នាសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី និងគ្រប់ផ្នែកទាំងអស់នៃក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ព្រមទាំងក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង បុគ្គលិក លោកគ្រូអ្នកគ្រូ និងអ្នកទទួលផលទាំងអស់សម្រាប់កិច្ចខំប្រឹងប្រែង និងការគាំទ្រដល់អង្គការមូលនិធិ ម៉េងលី ជេ. គួច ទាំងថវិកា សម្ភារ ការពង្រឹងសមត្ថភាព និងបច្ចេកទេស ដើម្បីឈានទៅរកសមិទ្ធផលជោគជ័យទាំងអស់នេះ។ យើងខ្ញុំទាំងអស់គ្នាក៏សូមសម្តែងអំណរគុណចំពោះលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ ដែលតែងតែផ្តល់ការគាំទ្រ និងធ្វើសកម្មភាពរៃអង្គាសថវិកាដើម្បីបរិច្ចាគមកកាន់អង្គការមូលនិធិ ម៉េងលី ជេ. គួច។ ប្រសិនបើគ្មានការគាំទ្រ និងការយកចិត្តទុកដាក់ពីអ្នកទាំងអស់គ្នានោះទេ យើងអាចនឹងប្រឈមបញ្ហាជាច្រើនដែលនឹងអាចកើតមានឡើង ជាពិសេសគឺកង្វះខាតហិរញ្ញវត្ថុតែម្តង។

ក្នុងនាមជាប្រធានគ្រប់គ្រងកម្មវិធី នាងខ្ញុំសូមសម្តែងនូវការអរគុណ និងសូមកោតសរសើរចំពោះទឹកចិត្តដ៏សប្បុរសរបស់អស់លោក លោកស្រីទាំងអស់គ្នា។

ដោយសេចក្តីគោរព និងរាប់អាន!

អ្នកស្រី យូ ម៉ាលែន

ថ្ងៃទី...........ខែ.................ឆ្នាំ២០២០

ទស្សនវិស័យ

ទស្សនវិស័យរបស់មូលនិធិ ម៉េងលី ជេ. គួច គឺចង់ឃើញប្រជាពលរដ្ឋ ដែលងាយរងគ្រោះ និងត្រូវបានគេរើសអើងទទួលបាននូវភាពស្មើគ្នាចំពោះសេវាអប់រំ សុខភាព ស្បៀងអាហារ និង តម្រូវការចាំបាច់ជាមូលដ្ឋាននានាដើម្បីឲ្យពួកគេរស់នៅក្នុងភាពល្អប្រសើរ និងមានភាពថ្លៃថ្នូរជាមនុស្សជាតិ នៅក្នុងរាជរដ្ឋាភិបាលកម្ពុ-ជា។

បេសកកម្ម

មូលនិធិ ម៉េងលី ជេ. គួច កំពុងរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ប្រកបដោយសន្តិភាព និងភាពសុខដុមរម្យនា តាមរយៈការផ្តល់នូវតម្រូវការចាំបាច់ជាមូលដ្ឋាន និងឱកាសដល់ប្រជាជន ដែល ងាយរងគ្រោះ និងត្រូវបានគេរើសអើង។

គោលដៅ

១. ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធអប់រំសម្រាប់សិស្សានុសិស្ស និងអត្រាសិស្សចុះឈ្មោះចូលរៀននៅតាមតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ជាពិសេសផ្តល់ការគាំទ្រដល់សិស្សានុសិស្សដែលងាយរងគ្រោះ ដើម្បីឱ្យពួកគេទទួលបានការសិក្សាល្អប្រសើរដូចសិស្សដទៃ។

២. ធ្វើឲ្យប្រសើរឡើងហេដ្ឋារចនាសម្ព័ន្ធសុខភាពនិងការទទួលបានសេវាសុខភាពដែលមានគុណភាព សម្រាប់ប្រជាពលរដ្ឋដែលងាយរងគ្រោះ។

៣. ធ្វើការអេអង្គាសថវិកា និងលើកកម្ពស់វប្បធម៌ចែករំលែក និងសកម្មភាពសប្បុរសធម៌ដើម្បីជួយគ្រួសារនិងកុមារដែលងាយរងគ្រោះ។

៤. បង្កើន និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយជាតិនិងអន្តរជាតិដើម្បីបុព្វហេតុមនុស្សធម៌។

៥. លើកទឹកចិត្ត និងបំផុសទេពកោសល្យ គំនិតច្នៃប្រឌិតក្នុងក្រុមយុវជន ដោយពឹងផ្អែក លើខ្លួនឯង និងការអនុវត្តជាក់ស្តែង ។

គុណតម្លៃរបស់មូលនិធិ ម៉េងលី ជេ. គួច

- ប្តេជ្ញាចិត្តធ្វើការជាមួយជនក្រីក្រ
- សន្សំសំចៃខ្ពស់
- ការឆ្លើយតបទាន់ពេល
- សាមគ្គីភាព

- បុគ្គលិក៖ ០៥នាក់ (ពេញម៉ោង)
- ថវិកាចំណូល៖ USD១៤៨,២៧០.៩០
- ថវិកាចំណាយ៖ USD១៥៩,៤៧៨.៧៩
- អ្នកទទួលផលសរុប៖៤១,៤១៥នាក់
- ស្រី៖ ២៤,៨៤៩ នាក់
- កុមារ៖ ១២,៤២៥នាក់
- ស្រី៖ ៧,៤៥៥នាក់
- តំបន់គោលដៅ៖ ២០ខេត្តក្រុង
- អ្នកទទួលផលជាគោលដៅ៖
  - គ្រួសារងាយរងគ្រោះ
  - ចាស់ជរា
  - កុមារងាយរងគ្រោះ

វឌ្ឍនភាពរបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច

2004
ត្រូវបានបង្កើតឡើងដោយដាក់ឈ្មោះថា វិទ្យាស្ថាន កម្ពុជាសម្រាប់សុខភាពកុមារ និងយុវជន (CICAH)

2007
បានជួយជួសជុលអគារសិក្សា១ខ្នងមាន៤បន្ទប់នៅសាលាបឋមសិក្សាថ្មកង្កែប គួច ប៉េងសាំង និនហួយ ក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង

2008
បានសាងសង់អគារសិក្សាថ្មី១ខ្នងមាន៤បន្ទប់នៅសាលាបឋមសិក្សាថ្មកង្កែប គួច ប៉េងសាំង និនហួយ ក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង

2013
ត្រូវបានប្តូរឈ្មោះពី វិទ្យាស្ថានកម្ពុជា សម្រាប់សុខភាពកុមារ និងយុវជន ទៅជាអង្គការមូលនិធិ ម៉េងលី ជេ. គួច និងត្រូវបានចុះបញ្ជីនៅប្រសួងមហាផ្ទៃ ចេញដោយសេចក្តីជូនដំណឹងលេខ ៩៧១ ស.ជ.ណ

2016
បានសាងសង់អគារសិក្សាថ្មី១ខ្នងមាន៤បន្ទប់នៅសាលាបឋមសិក្សាគួច ម៉េងលី ទួលបេង ក្នុងឃុំក្រឡាស្រុកកំពង់សៀម ខេត្តកំពង់ចាម

2018
- បានសាងសង់សាលាឆាន់ចំនួន១ខ្នង នៅក្នុងវត្តគិរីសេត្ថារាម
- ផ្តល់កង់ចំនួន១៦០គ្រឿងដល់សិស្សក្រីក្រចំនួន១៦០នាក់ នៅខេត្តកំពង់ឆ្នាំង
- កម្មវិធីអាហារសប្បុរសធម៌ លើកទី១៩៣ ដល់ប្រជាជនក្រីក្រចំនួន២៤៥គ្រួសារនៅស្រុកគៀនស្វាយ
- បានធ្វើសវនកម្មស្ថាប័នដោយក្រុមសវនករឯករាជ្យ និងទទួលបាន "Unqualified"

2019
- បានក្លាយជាសមាជិកពេញសិទ្ធិរបស់ CCC
- បានធ្វើវិសោធនកម្មលក្ខន្តិក និងរចនាសម្ព័ន្ធក្រុមប្រឹក្សា
- បានបញ្ចប់ជាស្ថាពរនៅឯកសារប្រវត្តិពីឆ្នាំ ២០០៦ ដល់ឆ្នាំ២០១៨
- ផលិតគោលនយោបាយចំនួន១០
- ទទួលបានការចូលរួមបរិច្ចាគថវិកាប្រចាំខែពីបុគ្គលិក MJQE

១. ប្រវត្តិសង្ខេបរបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច

វិទ្យាស្ថាន កម្ពុជា សម្រាប់សុខភាពកុមារ និងយុវជន គឺជាមូលនិធិក្នុងស្រុកមួយ ដែលមានគោលដៅក្នុងការផ្តល់នូវរាល់ព័ត៌មាន និងសេវាកម្មនានា ដែលទាក់ទងនឹងបញ្ហាសុខភាពទៅដល់កុមារ យុវជន និងមាតា ដែលជួបការលំបាកនៅក្នុងទីក្រុងភ្នំពេញ និងតាមជនបទដាច់ស្រយាល។ វិទ្យាស្ថាន កម្ពុជា សម្រាប់សុខភាពកុមារ និងយុវជន ត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមរបស់ ឯកឧត្តម ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី នៅក្នុងឆ្នាំ២០០៤ ដើម្បីជាមធ្យោបាយក្នុងការលើកកម្ពស់វិស័យអប់រំក្នុងចំណោមកុមារជាច្រើនដែលជួបការលំបាក តាមរយៈការផ្តល់អាហារូបករណ៍។ ចាប់តាំងពីការបង្កើតឡើងផ្ទត់គំនិតរបស់វិទ្យាស្ថានសម្រាប់សុខភាពកុមារ និងយុវជន ត្រូវបានអភិវឌ្ឍចេញជារូបរាងឡើងដោយមានគោលដៅ និងកម្មវត្ថុច្បាស់លាស់ ក្នុងគោលបំណងដើម្បីជួយលើកកម្ពស់សុខភាពរបស់កុមារនៅក្នុងប្រទេសកម្ពុជា។ កម្មវិធីជាច្រើនរបស់មូលនិធិ និងធ្វើកិច្ចសហប្រតិបត្តិការ និងបង្កើតនូវទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងសាលារៀន និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដទៃទៀត ដែលមានភាពសកម្មក្នុងវិស័យសុខភាព។

គោលដៅចម្បងរបស់មូលនិធិ គឺជួយលើកតម្កើងចំណេះដឹង និងផ្តល់នូវសេវាកម្មនានា ដែលជួយលុបបំបាត់នូវជំងឺផ្សេង ដែលប៉ះពាល់ដល់អាយុជិវិតកុមារក៏ដូចជាលើកកម្ពស់ការរស់នៅប្រកបដោយសុខភាពល្អ និងជួយអភិវឌ្ឍប្រាជ្ញាស្មារតី ផ្តល់តម្លៃ និងសុខមាលភាពរបស់កុមារ និងយុវជនងាយរងគ្រោះ ដើម្បីឱ្យជីវិតពួកគេត្រូវបានលើកកម្ពស់និងប្រកបដោយសក្តានុពលពេញលេញ។ ដើម្បីសំរេចបានបំណងប្រាថ្នាខាងលើ មានតែការលើកកម្ពស់វិស័យអប់រំ និងសិទ្ធិទទួលបាននូវធនធាននានានោះទេ ដែលធ្វើឱ្យយុវជនជួបការលំបាកទាំងនោះ អាចអភិវឌ្ឍនូវចំណេះដឹងរបស់ពួកគេបានល្អប្រសើរ ដែលឈានទៅរកការរីកលូតលាស់ប្រកបដោយសុខភាពល្អនៅក្នុងវ័យជំទង់របស់ពួកគេ។

ដើម្បីធានាឱ្យបានសកម្មភាពរបស់ខ្លួនកាន់តែទទួលបានជោគជ័យបន្ថែមទៀតនោះ នៅចុងឆ្នាំ២០១២ ស៊ីការ (CICAH) បានរៀបចំផែនការ និងដាក់ចេញនូវទស្សនវិស័យ គោលបំណង និងបេសកម្មយ៉ាងច្បាស់លាស់បន្ថែមទៀត រហូតដល់ដើមឆ្នាំ២០១៣ ស៊ីការ(CICAH) បានប្តូរឈ្មោះ ផ្លូវការទៅជា អង្គការមូលនិធិ ម៉េងលី ជេ. គួច ក្នុងឆ្នាំ២០១៣ ដែលបានចុះបញ្ជីទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ចេញដោយសេចក្តីជូនដំណឹងលេខ ៩៧១ ស.ជ.ណ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ត្រូវបានសរសេរជាភាសាអង់គ្លេស “Mengly J. Quach Foundation Organization”។ គម្រោងនេះបានដើរតួជាអង្គការក្រៅរដ្ឋាភិបាល ដែលបង្កើតឡើងក្នុងគោលដៅសប្បុរសធម៌ និងរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការជួយសម្រាលការលំបាករបស់ប្រជាជនក្រីក្រ និងឈានដល់ការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជាផងដែរ។

អង្គការមូលនិធិ ម៉េងលី ជេ. គួច បានពង្រីកសកម្មភាពរបស់ខ្លួន ដោយបានអនុវត្តសកម្មភាពតាមតំបន់គោលដៅ ក្នុងនោះមានកម្មវិធីធំៗចំនួន៤ រួមមានកម្មវិធីអប់រំ កម្មវិធីសុខភាព កម្មវិធីអភិវឌ្ឍសេវាសហគមន៍ និងកម្មវិធីឆ្លើយតបគ្រោះមហន្តរាយ។ ក្នុងនោះផងដែរ ដើម្បីឱ្យក្លាយជាអង្គការពេញលេញ និងប្រតិបត្តិការងារប្រកបដោយវិជ្ជាជីវៈ មានតម្លាភាព និងគណនេយ្យភាព ក្នុងខែមេសា ឆ្នាំ២០១៩ គណៈគ្រប់គ្រងអង្គការមូលនិធិ ម៉េងលី ជេ. គួច បានឯកភាពធ្វើវិសោធនកម្មលក្ខន្តិកៈ និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់អង្គការ និងបានស្នើសុំទទួលស្គាល់លក្ខន្តិកៈ និងរចនាសម្ព័ន្ធថ្មីទៅកាន់ក្រសួងមហាផ្ទៃ។

បច្ចុប្បន្ននេះ តាមរយៈសកម្មភាពមនុស្ស ធម៌ និងការរៃអង្គាសពីមូលនិធិនានា។ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានកំពុងអនុវត្តនូវគម្រោង ធំៗ ចំនួន១៥ នៅក្នុងទីក្រុងភ្នំពេញ ខេត្តកណ្តាល ខេត្តក្រចេះ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ចាម ដែលគម្រោងទាំងនេះរួមមាន៖

- គម្រោងកង់សម្រាប់ការអប់រំកុមារ
- គម្រោងសាងសង់សាលារដ្ឋ ម៉េងលី ជេគួច .
- គម្រោងអាហារូបករណ៍ ម៉េងលី ជេ .គួច
- គម្រោងបណ្ណាល័យចល័ត ម៉េងលី ជេគួច .
- គម្រោងគុណភាព ការបង្រៀន និងការសិក្សា
- គម្រោងសិក្ខាសាលាសប្បុរសធម៌ ឧកញ៉ា វេជ្ជបណ្ឌិតគួច ម៉េងលី
- គម្រោងឆ្លើយតបសង្គ្រោះបន្ទាន់ផ្នែកសុខភាព
- គម្រោងធនាគារឈាម ម៉េងលី ជេ .គួច
- គម្រោងគ្លីនិកព្យាបាលចល័ត វេជ្ជបណ្ឌិត គួច
- គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល
- គម្រោងឆ្លើយតបសង្គ្រោះបន្ទាន់
- គម្រោងធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ . គួច
- គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍
- គម្រោងអំណោយសប្បុរសធម៌
- គម្រោងគំនិតផ្តួចផ្តើមអាជីវកម្មវៃឆ្លាត

២. សមិទ្ធិផលសង្ខេប

ចាប់ពីខែមករារហូតខែធ្នូ ឆ្នាំ២០១៩ ក្នុងចំណោមគម្រោងទាំង២០នៃកម្មវិធីទាំង៤ អង្គការមូលនិធិម៉េងលី ជេ. គួច បានអនុវត្តគម្រោង ចំនួន១៥ ដោយមានអ្នកទទួលផលសរុបចំនួន៤១៤១៥នាក់។ ក្នុងកម្មវិធីអប់រំ មានគម្រោងចំនួន៦ត្រូវបានអនុវត្តក្នុងអំឡុងពេលចាប់ពីខែមករាដល់ខែធ្នូឆ្នាំ២០១៩ ដោយគម្រោងទាំង៦នោះរួមមាន គម្រោង កង់សម្រាប់ការអប់រំកុមារ មានកុមារទទួលផលចំនួន៨៤នាក់ គម្រោងសាងសង់



សាលារដ្ឋ ម៉េងលី ជេ. គួច មានអ្នកទទួលផលចំនួន២៩៤៨នាក់ គម្រោងអាហារូបករណ៍ ម៉េងលី ជេ. គួច មាននិស្សិតទទួលផលចំនួន១៣នាក់ គម្រោងបណ្ណាល័យចល័ត ម៉េងលី ជេគួច មានសិស្សានុសិស្សទទួលផលចំនួន១៧០០នាក់ គម្រោងគុណភាពការបង្រៀន និងការសិក្សា មានអ្នកទទួលផល៥៩៤៨នាក់ និងគម្រោងសិក្ខាសាលាសប្បុរសធម៌ ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី មានអ្នកទទួលផលសរុបចំនួន២៣០៥នាក់។ ក្នុងកម្មវិធីសុខភាព មានគម្រោងចំនួន៤ត្រូវបានអនុវត្ត ដូចជា គម្រោងឆ្លើយតបសង្គ្រោះបន្ទាន់ផ្នែកសុខភាព មានអ្នកទទួលផលចំនួន១៦នាក់ គម្រោងធនាគារឈាម ម៉េងលី ជេ. គួច មានសប្បុរសជនចូលរួមបរិច្ចាគឈាមចំនួន១៤នាក់ គម្រោងគ្លីនិកព្យាបាលចល័ត វេជ្ជបណ្ឌិត គួច មានអ្នកទទួលផលចំនួន៣៥៤នាក់ និងគម្រោងហេដ្ឋរចនាសម្ព័ន្ធសុខាភិបាល មានអ្នកទទួលផលចំនួន១៤៦៧០នាក់។ ដោយឡែកក្នុងកម្មវិធីសេវាសហគមន៍ មានគម្រោងចំនួន៥ត្រូវបានអនុវត្ត រួមមានគម្រោងឆ្លើយតបសង្គ្រោះបន្ទាន់ មានអ្នកទទួលផលចំនួន៣០១នាក់ គម្រោងធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច មានអ្នកទទួលផលចំនួន២៤៨១នាក់ គម្រោងហេ

ដ្ឋារចនាសម្ព័ន្ធសហគមន៍ មានអ្នកទទួលផលចំនួន៣៧៦៤នាក់ គម្រោងអំណោយសប្បុរសធម៌ មានអ្នកទទួលផលចំនួន៦៨០៥នាក់ និងគម្រោងគំនិតផ្តួចផ្តើមវៃឆ្លាតមានអ្នកទទួលផលចំនួន១២នាក់។

៣. សមិទ្ធិផលលម្អិត

៣.១. កម្មវិធីអប់រំ

យោងតាមផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំ២០១៩ អង្គការ មូលនិធិ ម៉េងលី ជេ.គួច បានសហការជាមួយអង្គការសង្គមស៊ីវិលក្នុងស្រុក អាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធនានា អនុវត្តគម្រោងចំនួន៦នៃកម្មវិធីអប់រំ ដែលមានអ្នកទទួលផលសរុបចំនួន១២៩៩៨នាក់ ស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្ត



កំពង់ចាម ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តក្រចេះ និងខេត្តព្រៃវែង។

៣.១.១ គម្រោង កង់សម្រាប់ការអប់រំកុមារ (CBE)

គម្រោងកង់សម្រាប់ការអប់រំកុមារ មានកុមារទទួលផលសរុបចំនួន៨៤នាក់ ដោយក្នុងនោះអង្គការ មូលនិធិ ម៉េងលី ជេ. គួច បានធ្វើសកម្មភាពគម្រោងកង់សម្រាប់អប់រំកុមារ លើទី១០កាលពីថ្ងៃទី១៧ ខែកញ្ញា

ឆ្នាំ២០១៩ ស្ថិតនៅក្នុងសង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយក្រុមការងារបានធ្វើការជ្រើសរើសកុមារក្រីក្របានចំនួន៧៩នាក់ ភាគច្រើនជាកូនរបស់អ្នករើសអេតចាយ អ្នកសុំទាន និងកម្មកររោងចក្រ ដើម្បីទទួលបានកង់ចំនួន៧៩គ្រឿង សម្រាប់ធ្វើជាមធ្យោបាយធ្វើដំណើរទៅសាលារៀន។ នៅថ្ងៃទី០១ ខែវិច្ឆិកា

ឆ្នាំ២០១៩ ក្រុមការងារអង្គការមូលនិធិ ម៉េងលី ជេ. គួច រួមសហការជាមួយសាលារៀន អន្តរទ្វីប អាមេរិកាំង បានធ្វើសកម្មភាពគម្រោង កង់សម្រាប់ការអប់រំកុមារ លើកទី១១ ស្ថិតនៅសាលាបឋមសិក្សា យុគន្ធរ ក្នុងឃុំផ្អុកទ្រូ ស្រុកបរិបូរណ៌ ខេត្តកំពង់ឆ្នាំង ដោយបានបរិច្ចាគកង់ចំនួន៥គ្រឿងជូនដល់សិស្សក្រីក្រចំនួន៥នាក់។

៣.១.២ គម្រោង សាងសង់សាលារដ្ឋ ម៉េងលី ជេ. គួច (MJQPSC)

កម្មវិធីសិក្សា សៀវភៅ និងបរិយាកាសសិក្សាត្រូវបានចាត់ទុកថាជាគោលការណ៍គ្រឹះទី៤ នៅក្នុងទស្សនៈវិស័យសម្រាប់កំណែទម្រង់វិស័យអប់រំនៅកម្ពុជា។ ការសាងសង់អគារសិក្សាបន្ថែម គឺជាផ្នែកមួយដ៏សំខាន់ក្នុងការពង្រីកលទ្ធភាពទទួលបានការអប់រំ ដើម្បីកែលម្អបរិស្ថានរៀនសូត្រឱ្យបានប្រសើរឡើង។ បើយោងតាមកម្មវិធីសន្និបាតអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៦ បានឱ្យដឹងថា អគារសិក្សាប្រមាណ៥០០០ខ្នង ត្រូវការសាងសង់ថ្មី និងជួសជុលកែលម្អជាបន្ទាន់។ ក្រសួងអប់រំបានអំពាវនាវទៅកាន់នាយករដ្ឋមន្ត្រី និងភាគីពាក់ព័ន្ធដើម្បីជួយសាងសង់អគារសិក្សាទាំងអស់នោះ។ ស្របពេលជាមួយគ្នានេះដែរ អង្គការមូលនិធិ ម៉េងលី ជេ. គួច ក៏មានគម្រោងសាងសង់អគារសិក្សាជូនសាលាដែលមានការខ្វះខាតខ្លាំង ជាពិសេសសាលានៅតាមតំបន់ដាច់ស្រយាលនានា នៃប្រទេសកម្ពុជា។ មូលនិធិ នឹងសាងសង់អគារសិក្សាជូនរដ្ឋ ឱ្យបានគ្រប់ខេត្តក្រុង នៃព្រះរាជាណាចក្រកម្ពុជា។

មូលនិធិ ម៉េងលី ជេ. គួច ក្នុងឆ្នាំ២០១៩ បានធ្វើគម្រោង សាងសង់សាលារដ្ឋ ម៉េងលី ជេ. គួច ដោយមានអ្នកទទួលផលសរុបចំនួន២៩៤០នាក់ ដោយក្នុងនោះ ក្នុងអំឡុងខែឧសភា ឆ្នាំ២០១៩ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានបរិច្ចាគថវិកាចំនួន៥០០០០០០រៀលជូនដល់សាលាបឋមសិក្សា គួច ម៉េងលី ទួលបេង មានសិស្សានុសិស្សសរុបចំនួន ៣៨៤នាក់ ស្ថិតក្នុងឃុំក្រទ្បា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ដើម្បីធ្វើការរៀបចំក្រាលតដ្ឋការ៉ូក្នុងបន្ទប់រៀនចំនួន២បន្ទប់។ ក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៩ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានសហការជាមួយសាលារៀន អន្តរទ្វីប អាមេរិកាំង សាខាទួលគោក បានពាំនាំយកថវិកាចំនួន១៦៥០ ដុល្លារអាមេរិក ដើម្បីធ្វើការសាងសង់បង្គន់អនាម័យចំនួន១ខ្នងមាន២បន្ទប់ និងមានរៀបចំសួនផ្កាចំនួន២សួន ជូនដល់សាលាបឋមសិក្សា ឈើទាល មានសិស្សានុសិស្សសរុបចំនួន៦៣៣នាក់ ក្នុងឃុំឫស្សីស្រុក

ស្រុកពាមជរ ខេត្តព្រៃវែង។ ក្នុងខែសីហា ឆ្នាំ២០១៩ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានធ្វើការបរិច្ចាគថវិកាចំនួន២៩៣៧ដុល្លារអាមេរិកជូនដល់សាលាបឋមសិក្សា ជាំសង្កែ ដែលមានសិស្សានុសិស្សចំនួន១៣៥១នាក់ ស្ថិតនៅក្នុងភូមិតានៃ ឃុំជាំសង្កែ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដើម្បីចូលរួមចំណែកសាងសង់អគារសិក្សា១ខ្នង ចំនួន៣បន្ទប់ សង់អំពីដែកស័ង្កសី។ ក្នុងព្រឹត្តិការណ៍សាលាសប្បុរសធម៌ ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី លើកទី៥ ស្ថិតនៅសាលប្រជុំនៃសណ្ឋាគារភ្នំប្រុស ខេត្តកំពង់ចាម លោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី នាយកប្រតិបត្តិនៃអង្គការមូលនិធិ ម៉េងលី ជេ. គួច បានធ្វើការបរិច្ចាគថវិកាចំនួន១០០០ដុល្លារអាមេរិក ដល់សាលាបឋមសិក្សាឈើខ្លឹម ដែលមានសិស្សានុសិស្សចំនួន៥២៦នាក់ស្ថិតនៅភូមិឈើខ្លឹម ឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដើម្បីរួមចំណែកជួយសាងសង់អគារសិក្សា១ខ្នង មាន២បន្ទប់ សង់ពីដែកស័ង្កសី។ ក្នុងឆ្នាំ២០១៩នោះផងដែរ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានសហការជាមួយមជ្ឈមណ្ឌលភាសា អេ អាយ អាយ នាំយកអំណោយជាបង្គន់អនាម័យចំនួន១ខ្នងមាន៣បន្ទប់ដែលមានតម្លៃ៤០០០ដុល្លារអាមេរិក ជូនដល់សាលាបឋមសិក្សាកោះរកគោ ដែលមានសិស្សានុសិស្សចំនួន៩៤នាក់ ស្ថិតនៅក្នុងភូមិអង្គ្រង ឃុំសំរោង

ស្រុកភ្នំក្រវ៉ាញ ខេត្តពោធិ៍សាត់។

៣.១.៣ គម្រោង អាហារូបករណ៍ ម៉េងលី ជេ. គួច (MJQS)

ដើម្បីដោះស្រាយឧបសគ្គក្នុងការដាក់បញ្ចូលឱ្យនិស្សិតងាយរងគ្រោះ និងមានជីវភាពក្រីក្រមកពីបណ្ដាខេត្តនានាបានចូលសិក្សារៀនសូត្រ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានបង្កើតឱ្យមាន អាហារូបករណ៍ ម៉េងលី ជេ. គួច ក្នុងគោលដៅធ្វើយ៉ាងណាជួយគាំទ្រផ្នែកហិរញ្ញវត្ថុនិស្សិតទាំងនោះ ឱ្យមានឱកាសបន្តការសិក្សារបស់ពួកគេ ដើម្បីជាប្រយោជន៍ដល់ខ្លួនឯង និងសង្គមជាតិនាពេលខាងមុខ។ គណៈកម្មការជ្រើសរើសអាហារូបករណ៍ធ្វើការវិភាគស៊ីជម្រៅទៅលើ "សិស្សក្រីក្រ" និងធ្វើការកំណត់នូវភាពខ្លាំង ក៏ដូចជាមុខជំនាញដែលពួកគេចាប់អារម្មណ៍មកសិក្សា ដើម្បីអភិវឌ្ឍអាជីពការងាររបស់ពួកគេឱ្យមានការរីកចម្រើននាពេលអនាគត។

ក្នុងអំឡុងឆ្នាំ២០១៩នេះ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានសហការជាមួយគណៈកម្មការអាហារូបករណ៍នៃផ្នែកប្រតិបត្តិការ ផ្តល់អាហារូបករណ៍ដល់និស្សិតដែលមានបញ្ហាសេដ្ឋកិច្ចគ្រួសារបានចំនួន១០នាក់ (អាហារូបករណ៍ថ្មី) និងនិស្សិតអាហារូបករណ៍ចាស់មានចំនួន៣នាក់។ ដូចនេះនិស្សិត

ដែលទទួលបានអាហារូបករណ៍សរុបសម្រាប់ឆ្នាំ២០១៩មានចំនួន១៣នាក់ ដែលក្នុងនោះមានព្រះសង្ឃចំនួន១អង្គផងដែរ។

៣.១.៤ គម្រោង បណ្ណាល័យចល័ត ម៉េងលី ជេ. គួច (MJQML)

គម្រោង បណ្ណាល័យចល័ត ម៉េងលី ជេ. គួច គឺជាគម្រោងផ្សព្វផ្សាយចំណេះទូទៅមួយដែលត្រូវបានអនុវត្តដោយអង្គការមូលនិធិ ម៉េងលី ជេ. គួច សម្រាប់អ្នកដែលមិនអាចប្រើប្រាស់សម្ភារសិក្សាបែបនេះនៅតាមតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជា។ គម្រោងបណ្ណាល័យចល័តត្រូវបានបង្កើតឡើងដើម្បីបម្រើជាប្រយោជន៍ដល់សហគមន៍នៅតាមតំបន់ដាច់ស្រយាលនានា ដែលមានការខ្វះខាតសម្ភារសិក្សា ដូចជា សៀវភៅអាន សៀវភៅរឿងព្រេង សៀវភៅគំនូរ។ល។ គម្រោង បណ្ណាល័យចល័ត ម៉េងលី

ជេ. គួច មានគោលបំណងបង្កើតលទ្ធភាព និងឱកាសដល់សិស្សានុសិស្ស ក៏ដូចជាកុមារតាមសហគមន៍

អាចចូលរួមសកម្មភាពសិក្សាក្រៅម៉ោងសិក្សាក្នុងសាលារដ្ឋដូចជា ការអានសៀវភៅ ការនិទានរឿង ការគូររូបគំនូរជាដើម។ ក្រៅពីការធ្វើសកម្មភាពខាងលើ គម្រោងបណ្ណាល័យចល័ត ម៉េងលី ជេ. គួច ក៏បានធ្វើសកម្មភាពបរិច្ចាគជាសម្ភារសិក្សាជូនដល់សិស្ស និងបរិច្ចាគជាសម្ភារបង្រៀនសម្រាប់ដាក់នៅក្នុងបណ្ណា-ល័យក្នុងសាលារៀន បណ្ណាល័យសហគមន៍ និងអង្គការ សមាគមនានាផងដែរ។

ក្នុងឆ្នាំ២០១៩នេះ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានអនុវត្តសកម្មភាពគម្រោង បណ្ណា-ល័យចល័ត ម៉េងលី ជេ. គួច បានចំនួន៩លើក ដោយមានសិស្សានុសិស្សចំនួន១៧០០នាក់បានទទួលផលផ្ទាល់ពីគម្រោងនេះ។ សកម្មភាពគម្រោង បណ្ណាល័យចល័ត ម៉េងលី ជេ. គួច ត្រូវបានអនុវត្តនៅក្នុងរាជធានីភ្នំពេញចំនួន៦លើកមានកុមារទទួលផលចំនួន១២១២នាក់ ដូចជានៅសាលាបឋមសិក្សាភូមិ៧ សាលាបឋមសិក្សា ទួលគោក អង្គការផ្ទះបាយកុមារ និងអង្គការសង្គ្រោះកុមារក្រីក្រអាស៊ីនៅកម្ពុជា។ អង្គ-ការមូលនិធិ ម៉េងលី ជេ. គួច បានធ្វើសកម្មភាពបណ្ណាល័យចល័ត ម៉េងលី ជេ. គួច ក្នុងខេត្តកណ្ដាល បានចំនួន២លើក នៅសាលាបឋមសិក្សា តាប្រាប និងអង្គការ Mlop Children's Home ដោយមានកុមារទទួលផលចំនួន២៦២នាក់ ហើយនៅខេត្តកំពង់ឆ្នាំងបានចំនួន១លើក ស្ថិតនៅសាលាបឋមសិក្សាយុគន្ធរ មានកុមារទទួលផលចំនួន២២៦នាក់។

៣.១.៥ គម្រោង គុណភាពការបង្រៀន និងការសិក្សា (TLQ)

គម្រោង គុណភាពការបង្រៀន និងការសិក្សា គឺជាគម្រោងថ្មីមួយក្នុងចំណោមគម្រោងទាំង៦នៃកម្មវិធីអប់រំ ត្រូវបានបង្កើតឡើងដោយក្រុមការងាររបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច កាលពីដើមឆ្នាំ២០១៩ និងត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយលោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី នាយកប្រតិបត្តិនៃអង្គការមូលនិធិ ម៉េងលី ជេ. គួច កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩។ គម្រោងនេះមានគោលបំណងដើម្បីលើកទឹកចិត្តសិស្សានុសិស្ស និងកុមារក្នុងសហគមន៍ ឱ្យមានចិត្តចង់សិក្សា និងរៀនសូត្រ ដើម្បីជំរុញ និងលើកកម្ពស់ប្រព័ន្ធអប់រំនៅកម្ពុជា។

ក្នុងពេលអនុវត្តសកម្មភាពនៃគម្រោង គុណភាពការបង្រៀន និងការសិក្សា ចាប់តាំងពីខែមករា រហូតដល់ខែធ្នូឆ្នាំ២០១៩ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានអនុវត្តសកម្មភាពជាក់ស្តែងបានចំនួន១២លើក មានអ្នកទទួលផលចំនួន៥៩៤៨នាក់ ស្ថិតនៅក្នុងតំបន់គោលដៅផ្សេងៗពីគ្នាចំនួន៦ខេត្តក្រុង ដូចជា រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តពោធិ៍សាត់ ខេត្តកំពង់ចាម និងខេត្តព្រៃវែង ដែលសមិទ្ធិផលចម្បងៗចេញពីការអនុវត្តគម្រោងនេះមានដូចជា ការបរិច្ចាគសៀវភៅអានដែលជាស្នាដៃនិពន្ធផ្ទាល់របស់លោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ជូនដល់ស្ថាប័នរដ្ឋ និងអង្គការសង្គមស៊ីវិល ការបរិច្ចាគកៅអីសិស្សដល់សាលារដ្ឋ ការបរិច្ចាគសម្ភារសិក្សាដល់សិស្ស និងសម្ភារបង្រៀន ការសាងសង់ក្តារខៀនព័ត៌មានក្នុងសាលារៀន និងការឧបត្ថម្ភថវិកាសម្រាប់ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងបរិវេណសាលារៀន។

៣.១.៦ គម្រោង សិក្ខាសាលាសប្បុរសធម៌ ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី (MJQCW)

គម្រោង សិក្ខាសាលាសប្បុរសធម៌ ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី គឺជាគម្រោងថ្មីមួយក្នុងចំណោមគម្រោងទាំង៦នៃកម្មវិធីអប់រំរបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច។ គម្រោងនេះ ត្រូវបានបង្កើតឡើង ផ្តោតសំខាន់លើគោលបំណង ចែករំលែកចំណេះដឹង និងចំណេះធ្វើដល់យុវជនជំនាន់ក្រោយ ក្នុងការត្រៀមខ្លួន និងជ្រើសរើសប្រធានបទត្រឹមត្រូវសម្រាប់ថ្នាក់ឧត្តមសិក្សា និងធ្វើការរៃអង្គាសថវិកាសម្រាប់ការងារសង្គម ការងារសប្បុរសធម៌ ឬឧបត្ថម្ភដល់មន្ទីរពេទ្យ ចាស់ជរាគ្មានទីពឹង គ្រួសារងាយរងគ្រោះនៅតាមតំបន់ដាច់ស្រយាលជាដើម ឬដើម្បីឧបត្ថម្ភដល់វិស័យអប់រំ ដូចជាការសាងសង់អគារសិក្សា សម្ភារសិក្សា

សម្ភារបង្រៀនជាដើម។ អង្គការមូលនិធិ ម៉េងលី ជេ. គួច បាននឹងកំពុងធ្វើកិច្ចសហការជាមួយបណ្តាក្រុមហ៊ុន អង្គការជាតិ អន្តរជាតិ សាកលវិទ្យាល័យ និងសហគ្រិនវ័យក្មេងជាច្រើន ដើម្បីរៀបចំសិក្ខាសាលាសប្បុរស-ធម៌ដល់យុវជន យុវនារី សិស្ស និស្សិតតាមស្ថាប័នអប់រំ បុគ្គលិកក្រុមហ៊ុន និងអង្គការនានាទាំងនៅក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានលោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយក ប្រតិបត្តិ នៃក្រុមហ៊ុន Mengly J. Quach Education ជាវាគ្មិនដ៏សំខាន់ក្នុងកម្មវិធីសិក្ខាសាលាសប្បុរសធម៌នោះ។ ក្រៅពីសិក្ខាសាលានៅក្នុងប្រទេស លោកឧកញ៉ា

វេជ្ជបណ្ឌិត គួច ម៉េងលី ក៏បានផ្តល់កិត្តិយសធ្វើជាវាគ្មិនក្នុងសិក្ខាសាលានៅក្រៅប្រទេសផងដែរដូចជា ប្រទេសកូរ៉េខាងត្បូង ប្រទេសថៃជាដើម...។

រហូតមកដល់ពេលរាយការណ៍នេះ គម្រោង សិក្ខាសាលាសប្បុរសធម៌ ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ត្រូវបានអនុវត្តបានចំនួន៦លើក ដោយមាននិស្សិត លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស បុគ្គលិកក្រុមហ៊ុន អង្គការជាតិ និងអន្តរជាតិចូលរួមសរុបចំនួន២៣០៥នាក់ ស្ថិននៅក្នុងខេត្តចំនួន៤ខេត្តដូចជា ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកំពង់ចាម និងក្នុងរាជធានីភ្នំពេញ។

៣.២. កម្មវិធីសុខភាព

ចាប់តាំងពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៩ អង្គការមូលនិធិ ម៉េងលី ជេ.គួច បានធ្វើការអនុវត្តគម្រោងចំនួន៤ក្នុងចំណោមគម្រោងទាំង៥នៃកម្មវិធីសុខភាព ដែលមានអ្នកទទួលផលសរុបចំនួន១៥០៥៤នាក់ ស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពត ខេត្តកំពង់ឆ្នាំង ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តព្រៃវែង និងខេត្តកណ្តាល។



៣.២.១ គម្រោង ឆ្លើយតបសង្គ្រោះបន្ទាន់ផ្នែកសុខភាព (HER)

អង្គការមូលនិធិ ម៉េងលី ជេ. គួច ជួយលើកកម្ពស់របៀបរស់នៅប្រកបដោយសុខភាពល្អនៅក្នុងសហគមន៍មួយចំនួននៅទូទាំងប្រទេសកម្ពុជា។ អង្គការមូលនិធិ បានកំពុងធ្វើសកម្មភាពដោយផ្សារភ្ជាប់គំនិតផ្តួចផ្តើមផ្នែកសុខភាពដើម្បីធានាថានិស្សិតក្រីក្រ ស្ត្រី ចាស់ជរា កុមារកំព្រា និងជនទីទ័លក្រមានភាពងាយរងគ្រោះខ្លាំងជាងគេ ទទួលបានជំនួយឧបត្ថម្ភសម្រាប់ការព្យាបាលជំងឺ និងការថែទាំសុខភាពបានល្អប្រសើរ។

ក្នុងឆ្នាំ២០១៩នេះ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានចំណាយថវិកាប្រមាណ៣០៣០៤ដុល្លារអាមេរិក សម្រាប់ការអនុវត្តគម្រោង ឆ្លើយតបសង្គ្រោះបន្ទាន់ផ្នែកសុខភាព ដោយបានផ្តល់ការគាំទ្រក្នុងការព្យាបាលអ្នកជំងឺចំនួន១៦នាក់ និងសមាជិកក្រុមគ្រួសាររបស់អ្នកជំងឺប្រមាណជាង២៥០នាក់។ ការជួយសម្រួលក្នុងការព្យាបាលអ្នកជំងឺទាំង១៦នាក់ រួមមានដូចជាអ្នកជំមហារីសុដន់ អ្នកជំងឺបេះដូង អ្នកជំងឺពកក អ្នកជំងឺផ្នែករោគស្ត្រី អ្នកគ្រោះថ្នាក់ចរាចរណ៍ជាដើម។ អ្វីគួរឱ្យកត់សម្គាល់ជាងនេះ ក្នុងខណៈពេលទទួល

បានព័ត៌មានដ៏សោកសង្រេងនៃការបាក់រំលំអគារនៅក្នុងខេត្តព្រះសីហនុកាលពីក្នុងខែមិថុនា ឆ្នាំ២០១៩ អង្គការមូលនិធិ ម៉េងលី ជេ. គួច ក៏បានសម្រេចបរិច្ចាគថវិកាចំនួន១០០០០ដុល្លារអាមេរិក តាមរយៈខុទ្ទកាល័យនៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជូនដល់ក្រុមគ្រួសារនៃជនរងគ្រោះទាំង២៨នាក់ផងដែរ។ ជាងនេះទៅទៀត រៀងរាល់ខែ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានបរិច្ចាគថវិកាចំនួន២០០០ដុល្លារក្នុង១ខែជូនដល់ក្រុមគ្រូពេទ្យផ្នែករថយន្តសង្គ្រោះបន្ទាន់ ដែលប្រចាំការនៅផ្លូវជាតិលេខ៤ ដើម្បីជួយសម្រួលដល់ជីវភាព និងការចំណាយប្រចាំថ្ងៃរបស់អង្គភាពផងដែរ។

៣.២.២ គម្រោង ធនាគារឈាម ម៉េងលី ជេ. គួច (MJQBB)

ដើម្បីរួមចំណែកជាមួយសង្គមក្នុងការលើកកម្ពស់សុខមាលភាពសង្គម និងមនុស្សជាតិ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានចូលរួមយ៉ាងសស្រាក់សស្រាំជាមួយរាជរដ្ឋាភិបាល ជាពិសេសស្ថាប័នសុខាភិបាល ក្នុងនោះទាំងការជួយសម្រួលការព្យាបាលជំងឺដល់ជនងាយរងគ្រោះ និងការស្វះស្វែងធនធានទាំងខាង

ក្នុង និងក្រៅដើម្បីជួយស្រោចស្រង់ជីវិតអ្នកដែលកំពុងត្រូវការជំនួយបន្ទាន់។ ក្នុងឆ្នាំ២០១៩នេះ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានធ្វើសកម្មភាពប្រមែប្រមូលក្រុមការងាររបស់ខ្លួនចំនួន១៤នាក់ និងបានធ្វើសកម្មភាព

បរិច្ចាគឈាមបានចំនួន១៤ប្លោក ដើម្បីជួយដល់អ្នកជំងឺដែលស្ថិតនៅក្នុងស្ថានភាពសង្គ្រោះបន្ទាន់ចំនួន៣នាក់ រួមមាន អ្នកជំងឺឈ្មោះ ជា សុខារី ដែលកើតមានជំងឺផ្នែករោគស្ត្រី សម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ ត្រូវការឈាមចំនួន៦ប្លោក។ អ្នកជំងឺឈ្មោះ ប៉ែន ចិន្តា ជាមិត្តភក្តិជិតស្និតរបស់អ្នកគ្រូ កែវ ធីតា ដែលកើតមានជំងឺខូច គ្រលៀន ហើយត្រូវការលាងឈាមជាប្រចាំ ត្រូវបានក្រុមការងារបរិច្ចាគឈាមជូនបានចំនួន២ប្លោក។ អ្នកជំងឺម្នាក់ទៀតឈ្មោះ រឿន រ៉ា ជាអ្នកជំងឺគ្រោះថ្នាក់ចរាចរណ៍សម្រាកព្យាបាលនៅមន្ទីរព្រះកុសុមៈ ត្រូវបានបរិច្ចាគឈាមចំនួន៦ប្លោក។

៣.២.៤ គម្រោង សាងសង់ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល (HIC)

អង្គការមូលនិធិ ម៉េងលី ជេ. គួច តែងតែផ្តល់ការគាំទ្រសកម្មភាពសុខភាពមួយចំនួន ដោយបានធ្វើការផ្តោតសំខាន់លើការដោះស្រាយដោយផ្ទាល់នូវភាពក្រីក្រ ភាពងាយរងគ្រោះ និងការឆ្លើយតបសង្គ្រោះបន្ទាន់ តាមរយៈការផ្តល់សេវាសុខភាពដល់សហគមន៍ នៅពេលមានតម្រូវការចាំបាច់ ឬខ្វះការគាំទ្រផ្នែកសុខភាព។ គោលបំណងសំខាន់នៃគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល គឺចូលរួមចំណែកលើកកម្ពស់គុណភាពសុខាភិបាលឱ្យប្រសើរឡើង ជាពិសេសរួមចំណែកពង្រឹងគុណភាពសេវាសុខភាព និងភាពងាយស្រួលសម្រាប់គ្រួសារ និងសហគមន៍ដែលងាយរងគ្រោះ។

ជាក់ស្តែងក្នុងឆ្នាំ២០១៩នេះ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានធ្វើការងាររបស់ខ្លួនដើម្បីរួមចំណែកក្នុងការពង្រឹងសេវាសុខាភិបាល ជាមួយរាជរដ្ឋាភិបាល ដោយក្នុងនោះមូលនិធិបានធ្វើការសាងសង់អណ្តូងទឹកស្អាតមួយផ្តល់ជូនមណ្ឌលសុខភាពដំរីផុង ក្នុងឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ ដែលអណ្តូងមួយនេះអាចផ្តល់ផលផ្ទាល់ដល់ប្រជាពលរដ្ឋចំនួន១៤១១៨នាក់ ដែលតែងតែស្វែងរកសេវាសុខភាពក្នុងមណ្ឌលសុខភាពមួយនេះ ព្រមទាំងផ្តល់ជាទឹកស្អាតដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំដំរីផុងទាំងមូលផងដែរ។ ជាមួយគ្នាផងដែរ ដើម្បីចូលរួមចំណែកអភិវឌ្ឍវិស័យសុខាភិបាល ក៏ដូចជាចង់បង្កើនចំនួនគ្រែពេទ្យ ដើម្បីឱ្យប្រជាពលរដ្ឋទូទៅបានមកស្នាក់នៅព្យាបាលជំងឺគ្រប់គ្រាន់តាមតម្រូវការ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានឧបត្ថម្ភគ្រែពេទ្យអេឡិកត្រូនិកទំនើបចំនួន២៣គ្រឿងដល់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំនួន២ រួមមានដូចជា ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ត្បែងមានជ័យ ខេត្តព្រះវិហារ ទទួលបានគ្រែពេទ្យចំនួន១៣គ្រែ និងការិយាល័យសុខាភិបាលប្រតិបត្តិ ឆ្លូង ខេត្តក្រចេះ ទទួលបានគ្រែពេទ្យចំនួន១០គ្រែ។

៣.៣. កម្មវិធីសេវាសហគមន៍

ប្រជាជន និងសហគមន៍ងាយរងគ្រោះទទួលបានការការពារ និងលើកកម្ពស់កម្រិតជីវភាពតាមរយៈសកម្មភាពអភិវឌ្ឍសហគមន៍ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធសហគមន៍ឱ្យប្រសើរឡើង។ កម្មវិធីនេះជាទូទៅត្រូវបានបង្កើតឡើងសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការថែរក្សាសុខុដុមរម្យនាសហគមន៍នានាក្នុងប្រទេសកម្ពុជា។ កម្មវិធីនេះមានគោលបំណង រួមចំណែកជួយសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍ ដូចជា បន្ទប់ទឹក អណ្តូង ផ្លូវថ្នល់ ស្ពាន និងការផ្តល់ការគាំទ្រចាំបាច់ដូចជា ការឆ្លើយតបសង្គ្រោះបន្ទាន់ផ្នែកគ្រឿងឧបភោគ បរិភោគ ការគាំពារសុវត្ថិភាព សម្លៀកបំពាក់ និងសម្ភារប្រើប្រាស់ចាំបាច់ជាមូលដ្ឋានដល់ប្រជាជនងាយរងគ្រោះនៅតំបន់ដាច់ស្រយាលបំផុតនៃប្រទេសកម្ពុជា។



ចាប់តាំងពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៩ មូលនិធិ ម៉េងលី ជេ.គួច បានធ្វើការអនុវត្តគម្រោងចំនួន៥ក្នុងចំណោមគម្រោងទាំង៦នៃកម្មវិធី សេវាសហគមន៍ ដែលមានអ្នកទទួលផលសរុបចំនួន១៣៣៦៣នាក់ ស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តបន្ទាយមានជ័យ និងខេត្តតាកែវ។

៣.៣.១ គម្រោង ឆ្លើយតបសង្គ្រោះបន្ទាន់ (ER)

អង្គការមូលនិធិ ម៉េងលី ជេ. គួច រួមចំណែកពង្រីកការផ្តល់ជំនួយឧបត្ថម្ភ និងជំនួយសង្គ្រោះបន្ទាន់ដល់ជនក្រីក្រ និងអ្នកខ្វះខាត នៅតាមសហគមន៍ជនបទនានាក្នុងប្រទេសកម្ពុជា។ អំណោយដែលបានផ្តល់ឱ្យពួកគេ ត្រូវបានធ្វើឡើងក្នុងគោលបំណង ជួយស្តារឡើងវិញ និងបន្តជីវភាពរស់នៅរបស់ជនងាយរងគ្រោះ។ អង្គការមូលនិធិ ម៉េងលី ជេ. គួច នៅតែបន្តឆ្លើយតបក្នុងការអភិវឌ្ឍជនបទ និងតំបន់ដាច់ស្រយាល។

ជាក់ស្តែងក្នុងរយៈពេល១២ខែ ចាប់តាំងពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៩នេះ អង្គការមូនិធិ ម៉េងលី ជេ. គួច បានអនុវត្តសកម្មភាពរបស់ខ្លួន ដោយបានធ្វើការឆ្លើយតបការសង្គ្រោះបន្ទាន់ដល់អ្នកទទួលផលសរុបចំនួន៣០១នាក់ ដែលក្នុងនោះរួមមានដូចជា ក្នុងអំឡុងខែមិថុនា ឆ្នាំ២០១៩ ក្រោយទទួលបានព័ត៌មានដ៏តក់ស្លុត និងរន្ធត់នៃការបាក់រលំអគារកម្ពស់៧ជាន់នៅខេត្តព្រះសីហនុ និងបានសម្លាប់ប្រជាជនសរុបចំនួន២៨

នាក់ និងបង្ករឱ្យរងរបួស២៦នាក់ អង្គការមូលនិធិ ម៉េងលី ជេ. គួច ដោយមានការចង្អុលបង្ហាញពីលោក ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី នាយកប្រតិបត្តិនៃអង្គការមូលនិធិ ម៉េងលី ជេ. គួច បាននាំយកថវិកាចំនួន ១០០០០ដុល្លារអាមេរិកបរិច្ចាគជូនដល់ក្រុមគ្រួសារនៃជនរងគ្រោះទាំង២៨គ្រួសារ។ ក្នុងឆ្នាំ២០១៩នេះផង ដែរ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានឧបត្ថម្ភដល់ការសាងសង់ផ្ទះថ្មី១ខ្នងជូនដល់ប្រជាពលរដ្ឋក្រីក្រ១ គ្រួសារ ដែលរស់នៅក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ ជាមួយគ្នាផងដែរ អង្គការមូលនិធិ ក៏បានឧបត្ថម្ភ ដល់ការជួសជុល និងកែលម្អរផ្ទះចំនួន៣ខ្នង របស់ប្រជាពលរដ្ឋ៣គ្រួសារ ដែលកំពុងមានជីវភាពខ្វះខាត ក្នុង ខេត្តកណ្តាល និងរាជធានីភ្នំពេញ។ ដំណាលគ្នាផងដែរ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានជួយឧបត្ថម្ភដល់ និស្សិតក្រីក្រចំនួន៤នាក់ ដើម្បីមានលទ្ធភាពរស់នៅ និងបន្តការសិក្សានៅក្នុងរាជធានីភ្នំពេញ ដូចជា ព្រះតេជ គុណ នឹម ចំរើនប្រាថ្នា និស្សិតឈ្មោះ ស៊ុន ថារ៉ា និស្សិតឈ្មោះ ដួង សូរិយា និងនិស្សិតឈ្មោះ តារា វិច្ឆ័យ។ ជាងនេះទៅទៀត អង្គការមូលនិធិ ម៉េងលី ជេ. គួច បានជួយសម្របសម្រួល និងឧបត្ថម្ភថវិកាសម្រាប់ការ ចំណាយនានាដល់ប្រជាពលរដ្ឋចំនួន៣នាក់ ខណៈពេលសម្រាកព្យាបាលជំងឺរបស់ខ្លួន។

៣.៣.២ គម្រោង ធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច (MJQFB)

គម្រោង ធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច ត្រូវបានបង្កើតឡើង ដើម្បីជួយដល់ ប្រជាជនក្រីក្រនៅក្នុងប្រទេសកម្ពុជា និងដើម្បីលើកកម្ពស់នូវវប្បធម៌ចែករំលែកនៅក្នុងសហគមន៍ផង ដែរ។ គម្រោង ធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច មានគោលដៅធ្វើយ៉ាងណាបង្កើននូវលទ្ធ ភាពងាយស្រួលជូនដល់សហគមន៍ណាដែលមានអត្រានៃភាពក្រីក្រខ្ពស់ ឱ្យពួកគេទទួលបាននូវរបប អាហារប្រកបដោយអនាម័យ ស្អាត និងជីវជាតិគ្រប់គ្រាន់ ព្រមទាំងអប់រំពួកគេឱ្យយល់ដឹងពីអនាម័យ និង ការបរិភោគប្រកបដោយឥរិយាបថត្រឹមត្រូវ។ មិនតែប៉ុណ្ណោះ យើងនឹងចូលរួមអភិវឌ្ឍសហគមន៍ណា ដែលមានការខ្វះខាតខ្លាំងលើចំណីអាហារ ពោលគឺធ្វើយ៉ាងណាឱ្យតម្រូវការ និងអ្នកប្រើប្រាស់មាន តុល្យភាពសមរម្យ។ តាមផែនការយុទ្ធសាស្ត្រ គម្រោង ធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច ត្រូវ បានធ្វើជាប្រចាំ យ៉ាងហោចណាស់១ដងក្នុង១ខែ ជាពិសេសនៅរៀងរាល់ថ្ងៃសីល។ ចាប់តាំងពីកកើត

គម្រោងនេះមក អង្គការមូលនិធិ ម៉េងលី ជេ. គួច បានធ្វើគម្រោងនេះបានចំនួន២១៥លើកមកហើយ ដោយមានអ្នកទទួលផលសរុបចំនួន៤៣៣១៤នាក់មកហើយ។

ដោយឡែកក្នុងដំណាក់កាលនៃរបាយការណ៍ចាប់ពីខែមករា រហូតដល់ខែធ្នូ ឆ្នាំ២០១៩នេះ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានធ្វើសកម្មភាពគម្រោង ធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច បានចំនួន១០លើក ដោយមានអ្នកទទួលផលសរុបចំនួន២៤៨១នាក់ ស្ថិតនៅក្នុង៣ខេត្តនិង១រាជធានី រួមមានរាជធានីភ្នំពេញ ខេត្តព្រះវិហារ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ ដែលសកម្មភាពទាំងនោះមានដូចជា ការបរិច្ចាគបបរគ្រឿង សម្លរការី នំបុ័ង បាយកញ្ចប់ និងគ្រឿងឧបភោគ បរិភោគ ជាដើម។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ ក្នុងខែកក្កដា ឆ្នាំ២០១៩ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានរៀបចំកម្មវិធីធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច លើកទី២០២ ស្ថិតនៅក្នុងសង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយបានបរិច្ចាគគ្រឿងឧបភោគ បរិភោគជូនដល់ប្រជាពលរដ្ឋចំនួន៣០០គ្រួសារ ដោយក្នុងមួយគ្រួសារទទួលបានអង្ករ១បាវ ទឹកស៊ីអ៊ីវ ទឹកត្រី អំបិល និងស្ករស។ ជាមួយគ្នាផងដែរ លោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី និងក្រុមគ្រួសារបានបរិច្ចាគថវិកាដល់ប្រជាពលរដ្ឋចំនួន៥០០នាក់ផងដែរ ដែលម្នាក់ៗទទួលបាន១០០០០រៀល។

៣.៣.៣ គម្រោង សាងសង់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ (CC)

គម្រោង សាងសង់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ត្រូវបានបង្កើតឡើង ដើម្បីចូលរួមចំណែកចូលរួមអភិវឌ្ឍសហគមន៍ តាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងតម្រូវការចាំបាច់ក្នុងមូលដ្ឋាន ដូចជា អណ្តូងទឹក បង្គន់អនាម័យ ឧបដ្ឋានសាលា ស្ពាន ផ្លូវ ជាដើម។ ចាប់តាំងពីឆ្នាំ២០០៤មក អង្គការមូលនិធិ ម៉េងលី ជេ. គួច បានបង្កើតសមិទ្ធផលធំៗជាច្រើនទាក់ទងនិងការសាងសង់ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ជាក់ស្តែងដូចជា ក្នុងឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង មូលនិធិបានសាងសង់ពិដាន

ព្រះវិហារ សាងសង់ខ្លោងទ្វារវត្ត សាងសង់ចេតិយរួមចំនួន១ សាងសង់ស្រះទឹកសហគមន៍ចំនួន១ សាងសង់បល្ល័ង្កព្រះក្នុងសាលាឆទានចំនួន១ និងឧបត្ថម្ភការគូរគំនូរចំនួន២០៧ម៉ែត្រការេ។ ក្នុងឆ្នាំ២០១៣មក អង្គការមូលនិធិ ម៉េងលី ជេ. គួច បានចូលរួមជាមួយអាជ្ញាធរមូលដ្ឋានឃុំរក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃ-វែង បានសាងសង់ស្ពាន១ខ្សែប្រវែង ១៨ម៉ែត្រ ទទឹង៤ម៉ែត្រ សាងសង់បង្គន់អនាម័យជូនអ្នកភូមិចំនួន ១៣បង្គន់ និងសាងសង់អណ្តូងទឹកចំនួន៣អណ្តូង។ ជាមួយគ្នាផងដែរ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានឧបត្ថម្ភថវិកាសម្រាប់ទិញរោងរៀបចំពិធីផ្សេងៗ តុចំនួន១០ និងកៅអីចំនួន១០០កៅអី ដើម្បីទុកសម្រាប់ប្រើប្រាស់នៅក្នុងសហគមន៍។

នៅក្នុងឆ្នាំ២០១៩នេះ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានធ្វើសកម្មភាពគម្រោង សាងសង់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ដោយមានអ្នកទទួលផលសរុបចំនួន៣៧៦៤នាក់ ដោយក្នុងនោះមូលនិធិបានធ្វើការសាងសង់ឧបដ្ឋានសាលា ១ខ្នងបន្ថែមទៀតក្នុងវត្តថ្មកង្កែប ស្ថិតនៅឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ ជាមួយគ្នាផងដែរ យើងក៏បានឧបត្ថម្ភថវិកាចំនួន២០០០ដុល្លារអាមេរិក ដើម្បីរៀបចំសាងសង់ខឿនព្រះវិហារ ស្ថិតក្នុងវត្តថ្មរៀង ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង

ផងដែរ។ មិនតែប៉ុណ្ណោះ អង្គការមូលនិធិ ម៉េងលី ជេ. គួច ក៏បានធ្វើសកម្មភាពរួមចំណែកសាងសង់សាលាបុណ្យ១ខ្នង ស្ថិតក្នុងស្រុកសង្គមមានជ័យ ខេត្តកំពង់ឆ្នាំង។

៣.៣.៤ គម្រោង អំណោយសប្បុរសធម៌ (GIK)

គម្រោង អំណោយសប្បុរសធម៌ ត្រូវបានបង្កើតឡើងនាចុងឆ្នាំ២០១៨ ហើយត្រូវបានអនុម័តជាផ្លូវការដោយលោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ក្នុងឆ្នាំ២០១៩នេះ។ គម្រោងនេះមានគោលបំណងសំខាន់ ជួយឧបត្ថម្ភជំនួយជាសម្ភារ និងថវិកា ដល់បុគ្គល ឬក្រុមងាយរងគ្រោះ ដើម្បីមានលទ្ធភាពរស់នៅប្រកបដោយភាពថ្លៃថ្នូរក្នុងសង្គម។

ក្នុងឆ្នាំ២០១៩នេះ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានអនុវត្តសកម្មភាពនៃគម្រោងអំណោយសប្បុរសធម៌ នៅក្នុងរាជធានីភ្នំពេញ និងខេត្តព្រះវិហារ ដោយមានអ្នកទទួលផលសរុបចំនួន ៦៨០៥នាក់។ ជាក់ស្តែង កាលពីខែមករា ឆ្នាំ ២០១៩ ក្រុមការងារអង្គការមូលនិធិ បាននាំយក

អំណោយសប្បុរសធម៌ជាអាវរងារចំនួន៣៣០អាវ និងមីកញ្ចប់ចំនួន៣៣០កេស ចែកជូនកងកម្លាំងទាហានការពារព្រំដែន ដែលកំពុងឈរជើងការពារស្ថិតនៅប្រាសាទព្រះវិហារ។ ក្នុងអំឡុងខែកញ្ញា ឆ្នាំ២០១៩ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានឧបត្ថម្ភថវិកាចំនួន៥០០០ដុល្លារអាមេរិកជូនដល់សន្និសីទលើកទី២ស្តីអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោករបស់ក្រសួងសាធារណការ និងដឹកជញ្ជូន សហការជាមួយអង្គការមូលនិធិបង្ការរបួសអាស៊ី។ អង្គការមូលនិធិ ម៉េងលី ជេ. គួច ក៏បានផ្តល់អំណោយសប្បុរសធម៌ជាម៉ាស៊ីនថតចម្លងថ្មី១គ្រឿងតម្លៃ១៩៧៥ដុល្លារអាមេរិកជូនដល់សង្កាត់អូឡាំពិក ក្នុងរាជធានីភ្នំពេញ ដើម្បីជួយសម្រួលការងារការិយាល័យ ដូចជាការថតចម្លង និងការបោះពុម្ពឯកសារនានា ជាពិសេសដើម្បីបង្កភាពងាយស្រួលដល់បុគ្គលិកដែលបម្រើការងារក្នុងសាលាសង្កាត់។

៣.៣.៥ គម្រោង គំនិតផ្តួចផ្តើមអាជីវកម្មវៃឆ្លាត (SS)

មិនខុសគ្នានិងគម្រោង អំណោយសប្បុរសធម៌ នោះទេ គម្រោង គំនិតផ្តួចផ្តើមអាជីវកម្មវៃឆ្លាតត្រូវបានបង្កើតឡើងនាចុងឆ្នាំ២០១៨ ហើយត្រូវបានអនុម័តជាផ្លូវការដោយលោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ក្នុងឆ្នាំ២០១៩នេះ។ គម្រោងនេះមានគោលបំណងសំខាន់ គឺលើកទឹកចិត្តយុវជនកម្ពុជា ក្នុងការប្រើប្រាស់សមត្ថភាពរបស់ខ្លួនបង្កើតនូវគំនិតថ្មីៗ ឬទេព្យកោសល ក្នុងការធ្វើផែនការអាជីវកម្មលេចធ្លោរ។

ក្នុងឆ្នាំ២០១៩ ដោយមើលឃើញពីគំនិតឆ្នៃប្រឌិតរបស់ក្រុមយុវជនសំរាមបឹងត្របែក លោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី តាមរយៈអង្គការមូលនិធិ ម៉េងលី ជេ. គួច បានឧបត្ថម្ភថវិកាចំនួន៥០០០ដុល្លារអាមេរិក និងសម្ភារហាងកាហ្វេមួយចំនួនជូនក្រុមយុវជនសំរាម រួមមានដូចជា តុផ្តៅមានកញ្ចក់ពីលើចំនួន០២ តុឈើកិនមានថត២ចំនួន០២ កៅអីសាឡុងផ្តៅចំនួន០៨ ឡាបូលាងដៃចំនួន០២ ឡាបូលាងចានចំនួន០១ និងកែវក្រដាសមានគម្របចំនួន១៥០០កែវ។

៣. ព័ត៌មានហិរញ្ញវត្ថុរបស់មូលនិធិ ម៉េងលី ជេ. គួច

ដើម្បីដំណើរការកម្មវិធីសំខាន់ខាងលើៗនេះ អង្គការមូលនិធិ ម៉េងលី ជេ. គួច ទទួលបានមូលនិធិគាំទ្រប្រចាំឆ្នាំពីបណ្ដាក្រុមហ៊ុនក្នុងប្រទេស និងសប្បុរសជនក្រៅប្រទេសមួយចំនួន សម្រាប់ទ្រទ្រង់មូលនិធិមួយនេះ បានសរុបចំនួន១៤៨,២៧០.៩០ដុល្លារអាមេរិក ដើម្បីប្រតិបត្តិសកម្មភាពរបស់ខ្លួន ដែលក្នុងនោះមានប្រមាណជា៨៥%(ប៉ែតសិបប្រាំភាគរយ)បានមកពីបរិច្ចាគរបស់ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ហើយប្រមាណជា១០%(ដប់ភាគរយ) គឺពីបណ្ដាសប្បុរសជនក្រៅប្រទេសដូចជា សហរដ្ឋអាមេរិក ប្រទេសស្វីស និងប្រទេសកូរ៉េជាដើម រីឯមានប្រមាណជា៥%(ប្រាំភាគរយ)ទៀតបានមកពីការបរិច្ចាគរបស់សប្បុរសជន និងក្រុមហ៊ុនក្នុងស្រុក។ ការបរិច្ចាគទាំងនោះមានដូចជា ធនធានជាសាច់ប្រាក់ ឬសម្ភារ និងផ្ដល់ជាជំនួយមកកាន់អង្គការមូលនិធិ ម៉េងលី ជេ. គួច ដើម្បីមានលទ្ធភាព បន្ថែមទៀតក្នុងការអនុវត្ត គម្រោងទាំង១៥របស់អង្គការមូលនិធិ។ ក្រៅពីនេះក្នុងឆ្នាំ២០១៩ ក្រុមការងារអង្គការមូលនិធិ ម៉េងលី ជេ. គួច បានបង្កើតកម្មវិធីរៃអង្គាសថវិកាពីសប្បុរសជននានាដូចជា ការបង្កើតប្រអប់បរិច្ចាគថវិកា កម្មវិធី លក់អាហារសប្បុរសធម៌តាមសាលារៀនរដ្ឋ និងសាលាឯកជននានា និងការប្រគំតន្ត្រីមនុស្សធម៌ជាដើម។ ថវិកាដែលទទួលបានសរុបប្រចាំឆ្នាំ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពបំផុត និងប្រកបដោយគណនេយ្យភាពខ្ពស់ ហើយក្នុងឆ្នាំ២០១៩នេះ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានចំណាយថវិកាសរុបចំនួន១៥៩,៤៧៨.៧៩ដុល្លារអាមេរិក សម្រាប់ការប្រតិបត្តិសកម្មភាពគម្រោងទាំង១៥។

៤. បទពិសោធមេរៀន និងបញ្ហានានា កើតឡើងក្នុងរយៈពេលរាយការណ៍

តាមរយៈការអនុវត្តគម្រោងទាំង១៥ខាងលើក្នុងរយៈពេល១២ខែនេះ ក្រុមការងារអង្គការមូលនិធិ ម៉េងលី ជេ. គួច បានសង្កេតឃើញថា សមិទ្ធផលនានា ដែលលេចចេញជារូបរាង គឺពិតជាបានផ្ដល់សារៈប្រយោជន៍យ៉ាងខ្លាំងដល់ប្រទេសកម្ពុជា និងប្រជាពលរដ្ឋខ្មែរក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគតផងដែរ។ ជាពិសេស បានរួមចំណែកដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋក្រីក្រ កុមារតូចៗដែលខ្វះខាតក្នុងការសិក្សា ជនពិការ និងជនគ្មានទីពឹងនានា។ ជាមួយគ្នាផងដែរ សមិទ្ធផលនានារបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច គឺទទួលការគាំទ្រ និងកិច្ចសហការយ៉ាងពេញទំហឹងពីអាជ្ញាធរក៏ដូចជាមន្ទីរ ជំនាញនានាផងដែរ។

ប៉ុន្តែ ស្របពេលដែលសមិទ្ធផលទាំងនេះកើតចេញជាផ្លែផ្កា ក្រុមការងារអង្គការមូលនិធិ ម៉េងលី ជេ. គួច ក៏បានជួបឧបសគ្គមួយចំនួនផងដែរ ក្នុងដំណើរការអនុវត្តសកម្មភាពរបស់ខ្លួន ក្នុងនោះមានដូចជា ក្រុមការងារមានគ្នាតិច ធៀបទៅនឹងទំហំការងារជាក់ស្តែង ជាហេតុធ្វើឱ្យសកម្មភាព មួយចំនួន មិនត្រូវបានអនុវត្ត

ទាន់តាមផែនការដែលបានគ្រោងទុក។ ការចុះប្រមូលទិន្នន័យជាបឋម មិនបានគ្រប់ ជ្រុងជ្រោយ បណ្តាលឱ្យមានការលំបាកមួយចំនួនក្នុងការគ្រប់គ្រងព័ត៌មាន ជាពិសេសចំនួនអ្នកទទួលផលពីគម្រោង នៅមិនទាន់បានធ្វើការកត់ត្រាច្បាស់លាស់។ ប្រព័ន្ធតាមដាន និងត្រួតពិនិត្យនៅមានកម្រិត ជាកត្តារាំងស្ទះដល់ឥទ្ធិពលនៃការវាយតម្លៃ ឬបំលាស់ប្រែវិជ្ជមានរបស់អ្នកទទួលផលក្រោយពេលដែលគម្រោងបានអនុវត្តសកម្មភាពរួចជាស្ថាពរ។

ថ្ងៃពុធ ៤កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ................ឆ្នាំ២០២០

ប្រធានគ្រប់គ្រងកម្មវិធី

អ្នកស្រី យូ ម៉ាលែន